ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០១៧.០៤២.ពស.ស

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO)
## លើកទី ៤

យោងតាមសេចក្តីជូនដំណឹងលេខ ធ១.០១៦.០៥៤.ពិសេស ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ ជ្រាបអំពីការដេញថ្លៃក្នុងប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០នាទីព្រឹក ដល់ ១២:០០នាទីថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧
- កាលវសាន : ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ៤០.០០០.០០០.០០០ (សែសិបប៊ីលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអតិបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន)រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និង អត្រាការប្រាក់ដេញថ្លៃជាភាគរយ(ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD(ជារៀលឬដុល្លារ) ត្រូវមានឥណប្រតិទាន យ៉ាងតិច បីខែ។ NCD ជាដុល្លារត្រូវកំណត់haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh ។ ក្នុងករណីដែលសារអេឡិចត្រូនិកមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ឲ្យបានមុនម៉ោង ១២:០០ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល ។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO ។

គណៈកម្មការរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការLPCO ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងមកនាយកដ្ឋានប្រតិបត្តិការ
តាមរយៈលេខទូរស័ព្ទ : ០១៧ ៤៩៨ ៥០៨ / ០៧៧ ៩៦១ ៩៩១